# ការបន្សាំខ្លួននឹងអាកាសធាតុ បំណុលលើសលុប និងមីក្រូហិរញ្ញវត្ថុ ភស្តុតាងថ្មីពីតំបន់ជនបទប្រទេសកម្ពុជា



**របាយការណ៍អំពីលទ្ធផលស្រាវជ្រាវ**

របាយការណ៍នេះ គឺជាផ្នែកមួយនៃគម្រោងស្រាវជ្រាវដ៏ធំដែលទទួលបានថវិកាស្រាវជ្រាវពីមូលនិធិ UK Research and Innovation’s Global Challenges ដែលមានចំណងជើងថា 'Depleted by Debt? ដោយផ្តោតទៅលើកញ្ចក់យេនឌ័រអំពីភាពធន់នឹងអាកាសធាតុ ឥណទាន និងអាហារូបត្ថម្ភនៅក្នុងប្រទេសកម្ពុជា និងប្រទេសឥណ្ឌាខាងត្បូង។ របាយការណ៍ដែលផ្តោតក្នុងប្រទេសកម្ពុជានេះបង្ហាញពីរបៀបនៃប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុកំពុងតែនាំទៅរកភាពអាសន្ននៃការជំពាក់លុយគេលើសលុប ដែលកាត់បន្ថយសមត្ថភាពនៃការបន្សុំាខ្លួន និងការស៊ូទ្រាំនៅក្នុងអាកាសធាតុមួយដែលកំពុងតែប្រែប្រួល។ របាយការណ៍ទី២ដែលផ្តោតលើប្រទេសកម្ពុជាបានកំណត់ថាវិបត្តិបំណុលនេះជាវិបត្តិសុខភាពសាធារណៈ ដែលបង្ហាញពីរបៀបដែលវិបត្តិទាំងពីរនេះកំពុងតែប្រតិកម្មនឹងគ្នាកាន់តែធ្ងន់ធ្ងរ និងនាំទៅរកទុក្ខលំបាកឃឹតៗដ៏រ៉ាំរ៉ៃក្នុងរយៈពេលយូរ។ ជាមួយគ្នានេះ វិបត្តិទាំងនេះបានផ្តល់នូវទិន្នន័យថ្មី និងគួរឱ្យទាក់ទាញអារម្មណ៍អំពីវិធីជាច្រើន ដែលនៅក្នុងនោះ សេចក្តីប្រាថ្នារបស់មនុស្សសម្រាប់ការបន្សុំាខ្លួនទៅនឹងការផ្លាស់ប្តូរអាកាសធាតុ និងសុខភាពល្អ ត្រូវបានជាប់អន្ទាក់ដោយបំណុល។



## សេចក្ដីសង្ខេប

ប្រាក់កម្ចីមីក្រូហិរញ្ញ វត្ថុកំពុងតែនាំទៅរកភាពអាសន្ន នៃការជំពាក់លុយគេលើសលុប ដែលកាត់បន្ថយសមត្ថភាពនៃការបន្សាំខ្លួន និងការតស៊ូនៅក្នុងអាកាសធាតុមួយដែលកំពុងតែប្រែប្រួល។

# សេចក្តីសង្ខេប

នៅពេលដែលអាកាសធាតុមិនអាចព្យាករណ៍បាន និងសីតុណ្ហភាពកំពុងតែកើនឡើងកំដៅកំណត់រូបរាងផ្សេងនៃបរិស្ថានសកលរបៀបនៃការបន្សុំាខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ គឺជាសំនួរមួយក្នុងចំនោមសំនួរដែលនាំមុខគេនៅក្នុងសម័យកាលរបស់យើង[1]។ ចម្លើយមួយដែលត្រូវបានស្នើឡើងកាលពីប៉ុន្មានឆ្នាំចុងក្រោយនេះ គឺការបង្កើនទំហំនៃមីក្រូហិរញ្ញវត្ថុទៅដល់តំបន់ងាយគ្រោះដោយបរិស្ថាន និងតំបន់ក្រីក្រ។ នេះគឺជាកម្មវិធីគោលនយោបាយដ៏លេចធ្លោមួយ ដែលចាប់ផ្តើមទាក់ទាញនូវកម្រិតនៃការវិនិយោគដ៏គួរអោយកត់សំគាល់ពីម្ចាស់ជំនួយធំៗ ដូចជាធនាគារពិភពលោក និងមូលនិធិអាកាសធាតុបៃតងរបស់អង្គការសហប្រជាជាតិ ក៏ដូចជាតួអង្គឯកជន និងស្ថាប័ននានា។ ជាសាកល ផលប័ត្រប្រាក់កម្ចីប៉ាន់ស្មានសរុបរបស់ស្ថាប័នគ្រឹះស្ថានហរិញ្ញវត្ថុបានកើនឡើងពី៩,៥៣ាន់លានដុល្លារនៅឆ្នាំ២០១៣ ដល់១២៤ពាន់លាននៅឆ្នាំ២០១៩[2] ប៉ុន្តែ នៅពេលដែលទិន្នន័យនៃការស្រាវជ្រាវក្នុងរបាយការណ៍នេះបានបង្ហាញថាការកើនឡើងយ៉ាងខ្លាំងនៅក្នុងការផ្តល់ប្រាក់កម្ចី គឺមិនបានជាប់ទាក់ទងគ្នាជាមួយនឹងសមត្ថភាពច្រើនជាងមុនដើម្បីបន្សុំាខ្លួនចំពោះភាពតក់ស្លុតនៃអាកាសធាតុ[3]។ ផ្ទុយទៅវិញ ការបន្សុំាខ្លួនទៅនឹងអាកាសធាតុដោយមីក្រូហិរញ្ញវត្ថុ គឺកំពុលនាំទៅរកភាពអាសន្ននៃបំណុលលើសលុប ដោយសារគ្រួសារនៅតាមជនបទកំពុងត្រូវការនូវយុទ្ធសាស្រ្តមួយបន្សុំាខ្លួនទៅនឹងគ្រោះថ្នាក់ និងការលះបង់សុខភាពដើម្បីសងបំណុលដែលកំពុងកើនឡើង។

ផ្អែកលើសំណុំទិន្នន័យដែលប្រមូលបានដោយវិធីសាស្រ្តចំរុះផ្សេងៗគ្នាដ៏ទូលំទូលាយ និងជាប្រភពដើម យើងបានផ្តល់ភស្តុតាងនូវការរកឃើញនៅក្នុងបរិបទនៃប្រទេសកម្ពុជា ដែលជាប្រទេសមួយក្នុងចំនោមប្រទេសដែលជំពាក់បំណុលមីក្រូហិរញ្ញវត្ថុច្រើនជាងគេនៅក្នុងពិភពលោក។ ទំហំកម្រិតនៃមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជាបានកើនដល់៤២១៣ ដុល្លារក្នុងម្នាក់នៅចុងឆ្នាំ២០២១ ដែលច្រើនជាងផលិតផលក្នុងស្រុកសរុប GDP ពីរដង[4]។ ប្រទេសនេះ ក៏ជាប្រទេសមួយក្នុងចំនោមប្រទេសដែលងាយរងគ្រោះបំផុតចំពោះការប្រែប្រួលអាកាសធាតុរបស់សកលលោក។ ភាពងាយរងគ្រោះចំពោះការប្រែប្រួលអាកាសធាតុនេះមានកំរិតខ្ពស់ ដូចជាភ្លៀងធ្លាក់ដែលមិនអាចព្យាករណ៍បាន ទឹកជំនន់ និងគ្រោះរាំងស្ងួតដែលកំណត់លទ្ធភាពជោគជ័យនៃជីវភាពរស់នៅរបស់អ្នកតូចតាច[5]។ អាស្រ័យលើការប្រែប្រួលនេះ កសិករដាំស្រូវ គឺងាយរងគ្រោះជាពិសេសចំពោះផលប៉ះពាល់ពីការប្រែប្រួលបរិស្ថាន និងអាកាសធាតុ ដោយសារតែការពឹងផ្អែករបស់ពួកគេទៅលើគំរូទឹកភ្លៀងធ្លាក់ដែលប្រែប្រួល។ កាលពី១០ឆ្នាំមុននៅក្នុងប្រទេសកម្ពុជា ឃើញមានទឹកជំនន់ធ្វើអោយខូតខាចដំណាំស្រូវ ផ្ទះសំបែង ហេដ្ឋារចនាសម្ព័ន្ធ និងសូម្បីតែសត្វចិញ្ចឹម ខណៈពេលដែលគ្រោះរាំងស្ងួតក៏បានបង្ហាញបញ្ហាស្រដៀងនេះដែរ។ ដូច្នោះ កសិករជាច្រើន គឺកំពុងត្រូវបានអំពាវនាវអោយទទួលយកការខាតបង់ដំណាំយ៉ាងធំ។ របាយការណ៍នេះបានបង្ហាញពីការរកឃើញកត្តាសំខាន់១២ អំពីទំនាក់ទំនងរវាងការប្រែប្រួលបិរស្ថាន និងអាកាសធាតុប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុ និងភាពជំពាក់លុយគេលើសលុបនៅតំបន់ជនបទប្រទេសកម្ពុជា។

**ជាជាងដោះស្រាយនូវភាពតក់ស្លុតរយៈពេលខ្លីនេះ មីក្រូឥណទានត្រូវបានបញ្ចូលទៅក្នុងជីវភាពរស់នៅដ៏ងាយរងគ្រោះ និងតានតឹង ដែលកំពុងធ្វើអោយថយចុះនូវសមត្ថភាពនៃការបន្សុំាខ្លួន និងការតស៊ូក្នុងរយៈពេលវែងនៅក្នុងករណីជាច្រើន។**

**ភាពមិនអាចគេចផុតពីបំណុលមីក្រូហិរញ្ញវត្ថុ**

ជាដំបូង ការប្រែប្រួលថ្មីៗនៅក្នុងទិដ្ឋភាពសេដ្ឋកិច្ចនយោបាយនៃការធ្វើកសិកម្មនៅប្រទេសកម្ពុជា -ត្រូវបានជំរុញដោយដំណើរការផលិតជាទំនិញ និងបង្កើនផលិតផលកសិកម្ម និងផលប៉ះពាល់នៃការប្រែប្រួលបរិស្ថាន និងអាកាសធាតុនៅក្នុងប្រទេស -បានប្រែក្លាយការខ្ចីប្រាក់ជាផ្លូវការ និងជាពិសេសការខ្ចីប្រាក់ពីមីក្រូហិរញ្ញវត្ថុទៅជាទិដ្ឋភាពនៃការធ្វើកសិកម្មមួយដែលមិនអាចជៀសបាននៅក្នុងអាកាសធាតុដែលកំពុងតែប្រែប្រួល។

**ភាពជំពាក់បំណុលលើសលុបជាយុទ្ធសាស្រ្តដោះស្រាយ**

ទីពីរ ការស្រាវជ្រាវបង្ហាញពីរបៀបដែលបំណុលទាក់ទងនឹងការធ្វើកសិកម្មទាំងនេះ នៅពេលដែលមានបំណុលហើយ វានឹងពិបាកប្រសិនបើមិនអាចសងត្រលប់វិញនៅក្នុងរយៈពេលវែង មានន័យថាភាពជំពាក់គេនឹងនៅតែមាន និងកាន់តែជ្រៅទៅៗតាមពេលវេលា។ ដូច្នោះ ជាជាងដោះស្រាយនូវភាពតក់ស្លុតរយៈពេលខ្លីនេះ យើងបង្ហាញពីរបៀបដែលមីក្រូឥណទានត្រូវបានបញ្ចូលទៅក្នុងជីវភាពរស់នៅដ៏ងាយរងគ្រោះ និងតានតឹង ដែលកំពុងធ្វើអោយថយចុះនូវសមត្ថភាពនៃការបន្សាំខ្លួន និងការតស៊ូក្នុងរយៈពេលវែងនៅក្នុងករណីជាច្រើន។ បន្ទាប់មកទៀត ភាពជំពាក់បំណុលបានក្លាយទៅជាការជំពាក់បំណុលកាន់តែច្រើនលើសលុប នៅពេលដែលអ្នកខ្ចីប្រឈមនឹងផលវិបាកបញ្ច្រាស ដូចជាតំលៃនៃភាពធន់ដោយហិរញ្ញវត្ថុរបស់ពួកគេ។ របាយការណ៍នេះផ្តល់នូវភស្តុតាងគួរអោយប្រុងប្រយ័ត្នអំពីមីក្រូហិរញ្ញវត្ថុចំពោះការបន្សាំខ្លួននឹងអាកាសធាតុ និងផ្តល់ជាជំរើសមធ្យោបាយឆ្ពោះទៅករការជួយគាំទ្រយ៉ាងខ្លាំងដល់ប្រជាពលរដ្ឋជនបទរបស់ប្រទេសកម្ពុជា។



# សេចក្ដីសង្ខេបនៃការរកឃើញ

## ភាពចាំបាច់នៃមីក្រូឥណទានសំរាប់ការធ្វើកសិកម្ម នៅក្នុងអាកាសធាតុដែលកំពុងប្រែប្រួលមួយ។

**៦៤%**

នៃអ្នកចូលរួមបានរាយការណ៍ថាមានការកើនឡើងនៅក្នុងការប្រើប្រាស់ជី និងថ្នាំគីមី បើប្រៀបធៀបទៅនឹង៥ឆ្នាំមុន។

**៦១%**

នៃគ្រួសារដែលធ្វើតែកសិករមួយមុខបានបង្កើនការប្រើប្រាស់ឥណទានរបស់ពួកគេ បើប្រៀបធៀបទៅ១០ឆ្នាំ។

**១៣%**

បានខ្ចីប្រាក់ពីគ្រឹះស្ថានហិរញ្ញវត្ថុដើម្បីសងប្រាក់កម្ចីផ្សេងទៀតខ្លះ។

**៥%**

នៃគ្រួសារដែលមានបំណុលបានលក់ដីកសិកម្មដើម្បីសងបំណង កាលពី១០ឆ្នាំមុន។

ទីផ្សារ និងសម្ពាធអេកូឡូស៊ី រួមគ្នាជាមួយនឹងការខ្វះខាតកំលាំងពលកម្មបាននាំឲ្យកសិករជាច្រើនផ្លាស់ប្តូរទៅរកប្រភេទស្រូវមួយចំនួនដែលចាំបាច់នូវការវិនិយោគដែលនាំទៅរកការជំពាក់បំណុលគេកាន់តែច្រើន។ ហេតុដូចនេះ កសិករជាច្រើនបានពឹងផ្អែកកាន់តែច្រើនឡើងទៅលើមីក្រូឥណទាន និងជាពិសេសឥណទានផ្លូវការ សំរាប់ផលិតកម្មកសិកម្ម។ នៅក្នុងអាកាសធាតុដែលកំពុងតែប្រែប្រួល គ្រួសារអ្នកធ្វើកសិកម្មកំពុងតែតស៊ូដ៏លំបាកជាមួយសីតុណ្ហភាពក្តៅ គ្រោះរាំងស្ងួត ទឹកជំនន់ ភ្លៀងធ្លាក់ដែលមិនអាចព្យាករណ៍បាន និងការកើនឡើងនៃសត្វល្អិតចង្រៃ។ កសិករកំពុងតែប្រើប្រាស់គ្រឿងម៉ាស៊ីន និងវត្ថុធាតុដើមគីមីកាន់តែច្រើន និងវិនិយោគនៅក្នុងប្រព័ន្ធធារាសាស្ត្រ។ ៦៤ភាគរយនៃកសិករបានរាយការណ៍ថាមានការកើនឡើងកាន់តែច្រើននៃការប្រើប្រាស់ជី និងថ្នាំគីមី បើប្រៀបធៀបទៅនឹង៥ឆ្នាំមុន។ ហើយ ៥៥ភាគរយនៃកសិករក៏បានរាយការណ៍ថាមានការកើនឡើងកាន់តែច្រើននៃការប្រើប្រាស់ជី បើប្រៀបធៀបទៅនឹងឆ្នាំមុន។

ការប្រមូលផលមិនបានជោគជ័យ ឬមិនល្អដោយសារតែលំនាំអាកាសធាតុខុសប្រក្រតីកាន់តែខ្លាំងឡើង ជំរុញឱ្យកសិករជាច្រើនធ្លាក់ក្នុងបំណុលកាន់តែច្រើន។ គ្រួសារកសិករត្រូវបានរកឃើញថាជាប់បំណុលយ៉ាងខ្លាំងច្រើនជាងគ្រួសារដែលមិនមែនជាកសិករ។ ៦១ភាគរយនៃអ្នកចូលរួមនៅក្នុងគ្រួសារកសិករបានរាយការណ៍ថាមានការកើនឡើងយ៉ាងខ្លាំងនៅក្នុងការប្រើប្រាស់ឥណទានសំរាប់ធ្វើកសិកម្ម បើប្រៀបធៀបទៅនឹង១០ឆ្នាំមុន។

# សេចក្ដីសង្ខេបនៃការរកឃើញ

## ភាពជំពាក់បំណុលលើសលុបជាយុទ្ធសាស្ត្រដោះស្រាយ

១

**ខ្ចីបន្ថែមទៀត**

ការតស៊ូដើម្បីបង់ប្រាក់កម្ចីដោយសារតែការប្រមូលផលមិនបានជោគជ័យ និងមិនល្អនាំកសិករ
អោយខ្ចីប្រាក់បន្ថែមទៀតដើម្បីបង់ប្រាក់កម្ចីដែលមានស្រាប់។ ១២,៥ភាគរយនៃអ្នកចូលរួមដែល
មានបំណុលបាននិយាយថានៅពេលចុងក្រោយនេះពួកគេបានខ្ចីប្រាក់ពីស្ថាប័នមីក្រូហិរញ្ញវត្ថុ
ដើម្បីសងផ្នែកខ្លះនៃប្រាក់កម្ចីផ្សេងមួយទៀត។ រីឯ អ្នកដ៏ទៃទៀតបានប្ដូរទៅខ្ចីប្រាក់ពីអ្នក
ចងការប្រាក់ក្រៅផ្លូវការ - នៅក្នុងអត្រាការប្រាក់ខ្ពស់ - ដើម្បីបង់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុ។

២

**ធ្វើការច្រើនជាងមុន**

សមាជិកគ្រួសារ រួមទាំងអ្នកចំណាកស្រុកមកទីក្រុង កំពុងតែធ្វើការជាច្រើនម៉ោងលើការងារ
ដោយប្រើប្រាស់កំលាំង និងរាង្គកាយច្រើន និងជួនកាលលើសពីការណែនាំរបស់ពេទ្យ។

៣

**លះបង់អាហារ**

“យើងត្រូវតែសងប្រាក់គេជាមុនសិន” គឺជាមូលហេតុជាទូទៅដែលបានមកពីគ្រួសារ
អ្នកជំពាក់លុយគេដែលកាត់បន្ថយបរិមាណ គុណភាព និងភាពចំរុះនៃអាហារ
ដែលពួកគេបានបរិភោគដើម្បីសង់ប្រាក់បំណុលអោយទាន់ពេលវេលា។

៤

**លក់ទ្រព្យសម្បត្តិ**

ភាគច្រើននៃគ្រួសារកសិករត្រូវតែលក់ទ្រព្យសម្បត្តិដើម្បីបង់ប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុនៅក្នុង
ពេលដែលមានការប្រមូលផលមិនបានជោគជ័យ និងមិនល្អ។ ៥,២ភាគរយនៃគ្រួសារ
ជំពាក់បំណុលបានលក់ដីកសិកម្មដើម្បីសងប្រាក់កម្ចីកាលពីកំឡុង១០ឆ្នាំចុងក្រោយនេះ។

៥

**ឈប់ធ្វើកសិកម្ម**

គ្រោះថ្នាក់ដែលទាក់ទងជាមួយនឹងការធ្វើស្រែនៅក្នុងពេលអាកាសធាតុកំពុងប្រែប្រួលនេះ
-បំណុលត្រូវបានបង្គរទៅលើកសិដ្ឋាន និងត្រូវបានយកមកដើម្បីដោះស្រាយជាមួយការប្រមូល
មិនបានជោគជ័យ និងមិនល្អ -បាននាំអោយគ្រួសារខ្លះឈប់ធ្វើកសិកម្ម។ អ្នកចំណាកស្រុក
ទៅឡូរេដ្ឋ និងប្រទេសថៃ គឺជាផ្លូវនៃការចំណាកស្រុកជាធម្មតាដែលត្រូវបានជ្រើសរើស។

# សេចក្តីសង្ខេបអនុសាស្រ្ត

១

**ការបន្ធូរបន្ថយបំណុល និងការសងបំណុលអាកាសធាតុ**

កម្មវិធីបន្ធូរបន្ថយនៃការប្រែប្រួល ដោយរួមមានទាំងការលើកលែងបំណុល គួរតែត្រូវបានបង្កើតនូវកម្រិតគ្រួសារដើម្បីអនុញ្ញាតអោយអ្នកខ្ចីបិតនៅក្នុងទីតាំងមួយល្អប្រសើរជាងមុនដើម្បីកាត់បន្ថយ និងបន្សាំខ្លួនទៅនឹងផលប៉ះពាល់នៃការប្រែប្រួលបរិស្ថាន និងអាកាសធាតុ។ កម្មវិធីបែបនេះគួរតែដើរទន្ទឹមគ្នាជាមួយនឹងការជំនួសនៃប្រាក់កម្ចីមីក្រូហិរញ្ញវត្ថុពាណិជ្ជកម្មជាមួយនឹងការផ្ទេរសាច់ប្រាក់ដោយគ្មានលក្ខខណ្ឌ រួមជាមួយនឹងការពង្រីក មិនត្រឹមតែប្រព័ន្ធបទប្បញ្ញត្តិសង្គមដ៏ខ្លាំងក្លាមួយទេ ប៉ុន្តែទាំងស្ថាប័នគ្រប់គ្រងដោយសហគមន៍ និងជាកម្មសិទ្ធិរបស់សហគមន៍ សម្រាប់ការអភិវឌ្ឍន៍បៃតង និងការបន្សាំខ្លួននឹងអាកាសធាតុ។ ស្ថាប័នទាំងនេះនឹងត្រូវបានផ្តល់ហិរញ្ញប្បទានដោយលំហូរនៃការផ្ទេរប្រាក់ពី Global North (ត្រលប់) ទៅ Global South នៅកម្រិតធំជាងមុនយ៉ាងច្រើនជាងការសន្យាដែលមិនបានបំពេញ និងមិនគ្រប់គ្រាន់ចំនួន១០០ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ។

២

**ការផ្តល់នូវការគាំទ្រហិរញ្ញវត្ថុសារជាថ្មី**

បើទោះបីជាមិនទាំងអស់ ផ្នែកដ៏ធំមួយនៃការគាំទ្រហិរញ្ញវត្ថុរបស់សហគមន៍អភិវឌ្ឍន៍អន្តរជាតិដ៏សំខាន់ដែលត្រូវបានផ្តល់ដោយសប្បុរសទៅអោយស្ថាប័នមីក្រូហិរញ្ញវត្ថុដែលមានម្ចាស់ជាអ្នកវិនិយោគបរទេសដ៏ធំ និងបានចំណេញយ៉ាងច្រើន គួរតែត្រូវបានផ្តល់ជូនឡើងវិញទៅក្នុងការគាំទ្រចំពោះធនាគារអភិវឌ្ឍន៍ សហគមន៍ហិរញ្ញវត្ថុ និងសហជីពឥណទាន ដែលជាជាស្ថាប័នផ្អែកលើសហគមន៍ ដែលទទួលបានការលើកទឹកចិត្តច្រើនជាងមុន និងជំនាញក្នុងការណែនាំវិធានការចាំបាច់ ដើម្បីដោះស្រាយគ្រោះអាសន្នអាកាសធាតុ។

៣

**ការយកពន្ធ**

លំហូរចេញនៃតម្លៃដ៏ច្រើនពីប្រទេសកម្ពុជាដែលបង្កើតដោយស្ថាប័នមីក្រូហិរញ្ញវត្ថុនាំមុខគេដែលមានម្ចាស់ជាបរទេសគួរតែត្រូវបានយកពន្ធ និងប្រាក់ដែលធ្លាប់ផ្តល់ទៅក្នុងកញ្ចប់ថវិកាមូលនិធិជាតិនៅមូលដ្ឋាន គួរតែត្រូវបានរចនាឡើងដោយជាក់លាក់ដើម្បីដោះស្រាយគ្រោះអាសន្ននៃអាកាសធាតុ។ វិធានការនេះ ក៏នឹងធ្វើឱ្យយឺតយ៉ាវផងដែរដល់កំណើននៃការផ្តល់ប្រាក់កម្ចី ដែលជំរុញដោយវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។

៤

**Fintech ជាកម្មសិទ្ធិរបស់សហគមន៍**

ការណែនាំអំពីកម្មវិធី Fintech មួយចំនួន (បច្ចេកវិទ្យាហិរញ្ញវត្ថុ)ដែលជាកម្មសិទ្ធិរបស់សហគមន៍ដែលមានសមត្ថភាពទាញយកប្រយោជន៍ពីរបកគំហើញបច្ចេកវិទ្យាថ្មីនេះ ដោយជួយសម្រួលអោយមានការចំណាយទាបជាងមុនក្នុងការឆ្លើយតបក្នុងតំបន់សំខាន់ៗបន្ថែមទៀតចំពោះភាពអាសន្នអាកាសធាតុ។

កម្មវិធីបន្ទូរបន្ថយនៃការផ្លាស់ប្តូរ រួមទាំងការលើកលែង
បំណុល គួរតែត្រូវបានបង្កើតឡើងនៅកម្រិតគ្រួសារ
ដើម្បីអនុញ្ញាតឱ្យអ្នកខ្ចីមានស្ថានភាពកាន់តែប្រសើរ
ឡើង ដើម្បីកាត់បន្ថយ និងសម្របខ្លួនទៅនឹងផល
ប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងបរិស្ថាន។



# វិធីសាស្ត្រស្រាវជ្រាវ

របាយការណ៍នេះបង្ហាញពីការស្រាវជ្រាវនៅក្នុងភូមិ៣នៅក្នុងខេត្តព្រៃវែង ខេត្តកំពង់ចាម និងខេត្តបាត់ដំបងដែលចាប់ផ្តើមពីដំបូងចន្លោះពីខែតុលា ឆ្នាំ២០២០ ដល់ខែកុម្ភៈ ឆ្នាំ២០២២។

**របាយការណ៍នេះបង្ហាញពីការស្រាវជ្រាវនៅក្នុងភូមិ៣នៅក្នុងខេត្តព្រៃវែង ខេត្តកំពង់ចាម និងខេត្តបាត់ដំបងដែលចាប់ផ្តើមពីដំបូងចន្លោះពីខែតុលា ឆ្នាំ២០២០ ដល់ខែកុម្ភៈ ឆ្នាំ២០២២។**
ការស្ទង់មតិគ្រួសារបែបបរិមាណចំនួន៦២១ បន្ថែមដោយបញ្ជីសំនួរជាលក្ខណៈឯកជនចំនួន១២២០ ត្រូវបានអនុវត្តនៅក្នុងភូមិ៣ ដោយមានភាពងាយរងគ្រោះផ្សេងៗគ្នាចំពោះគ្រោះរាំងស្ងួត ទឹកជំនន់ និងមានភាពពឹងផ្អែកខុសៗគ្នាទៅលើកសិកម្មផ្អែកលើដំណាំស្រូវ។ ការស្ទង់មតិនេះបានកំណត់ភូមិសាស្ត្រ មុខរបរគ្រួសារ ប្រវត្តិនៃការចំណាកស្រុក ទ្រព្យសម្បត្តិគ្រួសារ និងបំណុលប្រាក់សន្សំ ការខ្ចីប្រាក់ និងបទពិសោធន៍ក្នុងការអោយខ្ចីប្រាក់ ព្រមទាំងបទពិសោធន៍នៃសមត្ថភាពបន្សាំខ្លួនទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

**ការពិព័ណ៌នាអំពីបរិស្ថាននៃភូមិសិក្សា (ខែមករា ឆ្នាំ២០១៨ ដល់ ខែធ្នូ ឆ្នាំ២០២១)**
ការសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធជាមួយអ្នកភូមិ និងអ្នកពាក់ព័ន្ធក្នុងស្រុកត្រូវបានធ្វើឡើងដើម្បីបន្ថែមទៅការប្រមូលទិន្នន័យ GIS មានស្រាប់ និងជាបឋម ការប្រមូលទិន្នន័យអំពីកសិកម្ម អាកាសធាតុ និងបរិស្ថានដែលមានស្រាប់ ហើយនឹងការថតរូបជាឯកសារបានជួយដល់ការវិភាគអំពីការប្រែប្រួលអេកូឡូស៊ីសង្គមតាមរដូវ និងប្រចាំឆ្នាំនៅក្នុងភូមិទាំងបីនេះ។

**ការសម្ភាសន៍បែបគុណភាពជាមួយអ្នកភូមិ (មីនា ដល់ ឧសភា ឆ្នាំ២០២១)**
ការសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធត្រូវបានអនុវត្តនៅក្នុងភូមិ០៣ ដោយមាន៣០ គ្រួសារ (ជាមធ្យម អ្នកចូលរួម៦០នាក់)។ ចំពោះគ្រួសារនីមួយៗ  សមាជិកគ្រួសារ២រូបត្រូវបានសម្ភាសន៍ ដែលជាញឹកញ៉ាប់ រួមមានទាំងប្តីប្រពន្ធ។ ជាដំបូង សំណាកគំរូនៃគ្រួសារត្រូវបានស្រង់ចេញពីការស្ទង់មតិគ្រួសារបែបបរិមាណ ដែលតំណាងឱ្យកម្រិតផ្សេងៗនៃបំណុល។ បន្ទាប់មក ៤គ្រួសារនៅក្នុងស្រទាប់ប្រភេទនីមួយៗនៃបំណុល៥ប្រភេទទាំងនេះត្រូវបានយកមកធ្វើជាសំណាក ដោយផ្អែកលើទិន្នន័យស្ទង់មតិអំពីកម្មសិទ្ធិដីប្រភពបំណុល ព្រមជាមួយគន្លងនៃការចំណាកស្រុក។

**ការសម្ភាសន៍ដោយរូបភាព (មីនា-ឧសភា ឆ្នាំ២០២១)**
អ្នកស្រាវជ្រាវបានផ្តល់កាមេរ៉ាទៅ១៥គ្រួសារ (ដោយមានអ្នកចូលរួម៣០នាក់ ស្មើនឹងពាក់កណ្តាលនៃអ្នកចូលរួមសម្ភាសន៍បែបគុណភាព) រយៈពេល១អាទិត្យ ដោយសុំអោយពួកគាត់ថតរូបភាពនៃធាតុសំខាន់ៗនៃជីវភាពរស់នៅរបស់ពួកគេ ដែលទាក់ទងនឹងម្ហូបអាហារ និងជាពិសេស បញ្ហាប្រឈមហិរញ្ញវត្ថុ។ បន្ទាប់មកទៀត ក្រុមអ្នកស្រាវជ្រាវបានសម្ភាសន៍ជាមួយពួកគេតាមរយៈទូរស័ព្ទ ដែលនៅក្នុងនោះ រូបភាព និងមូលហេតុនៃការថតរូបភាពត្រូវបានយកមកពិភាក្សា។

# កំណត់នៅចុងអត្ថបទ

1 ការបន្សាំខ្លួន មាននិយមន័យជា “ដំណើរការនៃការកែតម្រូវទៅនឹងអាកាសធាតុជាក់ស្តែង ឬរំពឹងទុក និងផលប៉ះពាល់របស់វា” (IPCC, 2014)។

2 ការបញ្ចូលគ្នា (២០១៩) ឧបករណ៍វាស់ស្ទង់មីក្រូហិរញ្ញវត្ថុ ២០១៩។ បារីស៖ ការបញ្ចូលគ្នា។ [អនឡាញ] អាចរកបានពី៖ http://www.convergences.org/en/104906-2/> (ចូលប្រើថ្ងៃទី 17 ខែមិថុនា ឆ្នាំ 2022)។

3 ភាពធន់ គឺមាននិយមន័យថា៖ “សមត្ថភាពនៃប្រព័ន្ធបរិស្ថាន សេដ្ឋកិច្ច និងសង្គមដើម្បីដោះស្រាយជាមួយការរំខាន និន្នាការ ឬព្រឹត្តិការណ៍គ្រោះថ្នាក់ដោយឆ្លើយតប ឬរៀបចំឡើងវិញនូវវិធីដែលរក្សារចនាសម្ព័ន្ធ អត្តសញ្ញាណ និងមុខងារសំខាន់របស់ពួកគេ ស្របពេលដែលរក្សានូវសមត្ថភាពសំរាប់បន្សាំខ្លួន រៀនសូត្រ និងផ្លាស់ប្តូរផងដែរ” (IPCC, 2014)។

4 សម្ភាសន៍ជាមួយអ្នកជាន់ខ្ពស់ម្នាក់នៃសមាគមន៍មីក្រូហិរញ្ញវត្ថុកម្ពុជា (កុម្ភៈ ឆ្នាំ២០២២)។

5 លទ្ធភាពងាយរងគ្រោះ គឺជា “ទំនោរ ឬទំនោរចិត្តដែលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ លទ្ធភាពងាយរងគ្រោះមាននៅក្នុងធាតុ និងទស្សនៈផ្សេងៗគ្នារួមមានភាពរសើប និងភាពងាយបង្កជាគ្រោះថ្នាក់ និងខ្វះសមត្ថភាពដោះស្រាយ និងសម្របខ្លួន” (IPCC, 2014)។

**របាយការណ៍លទ្ធផលនៃការស្រាវជ្រាវ**

Vincent Guermond, Laurie Parsons, Long Ly Vouch, Katherine Brickell, Sébastien Michiels, Gráinne Fay, Milford Bateman, Giacomo Zanello, Nithya Natarajan, Dalia Iskander, Fiorella Picchioni កញ្ញា ឆ្នាំ 2022។
របាយការណ៍នេះត្រូវបានបោះពុម្ពនៅឆ្នាំ 2022 ដោយ Royal Holloway សាកលវិទ្យាល័យឡុងដ៍ សាកលវិទ្យាល័យ King's College ទីក្រុងឡុងដ៍ សាកលវិទ្យាល័យ Reading សាកលវិទ្យាល័យ University College ទីក្រុងឡុងដ៍ និងសាកលវិទ្យាល័យ Greenwich ក្រោមអាជ្ញាប័ណ្ណ Creative Commons Attribution-Non Commercial 3.0 ។

**ព័តមាននៃការដកស្រង់**

Guermond, V., Parsons, L., Ly Vouch, L., Brickell, K., Michiels, S., Fay, G., Bateman, M., Zanello, G., Natarajan, N., Iskander, D., និង Picchioni, F. (2022) ។ មីក្រូហិរញ្ញវត្ថុ បំណុលលើសលុប និងការបន្សាំអាកាសធាតុ៖ ភស្តុតាងថ្មីពីជនបទប្រទេសកម្ពុជា។ Royal Holloway សាកលវិទ្យាល័យឡុងដ៍។

**ការថតរូប**

Sopheak Chann, Sophal Neak and Thomas Cristofoletti.

**ការរចនារបាយការណ៍**

Bison Bison www.bisonbison.co.uk.

**ចំណាំ**

របាយការណ៍នេះ និងអនុសាស្ត្រ ព្រមទាំងលទ្ធផលរបស់វា គឺផ្អែកទៅលើការវិភាគ និងស្រាវជ្រាវរបស់អ្នកនិពន្ធតែប៉ុណ្ណោះ។ របាយការណ៍នេះមិនបានឆ្លុះបញ្ចាំងអំពីទស្សនៈរបស់អ្នកថតរូប និងអ្នកសិល្បៈដែលបានចូលរួមក្នុងការសិក្សានេះទេ។